ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង



# របាយការណ៍

# ស្តីពីលទ្ធផលការងារសម្រេចបានឆ្នាំ២០១៨ និងទិសដៅការងារ អនុវត្តបន្តឆ្នាំ២០១៩

# របស់មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង

ក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨

និងលើកទិសដៅអនុវត្តការងារឆ្នាំ២០១៩

របស់ក្រសួងមុខងារសាធារណៈ

រាជធានីភ្នំពេញ,ថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០១៩

នៅភោជនីយដ្ឋានទន្លេបាសាក់II រាជធានីភ្នំពេញ

រៀបចំដោយៈ លោក ញ៉ែម សុខជា ប្រធានមន្ទីរមុខងារសាធារណៈខេត្តព្រៃវែង

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ១. ស្ថានភាពទូទៅ ៖

មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង មានរចនាសម្ព័ន្ធគ្រប់គ្រងចំនួនបីការិយាល័យគឺ៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យក្របខណ្ឌ និងបណ្តុះបណ្តាល
- ការិយាល័យត្រួតពិនិត្យរដ្ឋបាល និងបៀវត្ស

- សព្វថ្ងៃមន្ទីរមានមន្ត្រីរាជការសរុបចំនួន១៩ នាក់ ស្រីចំនួន០៦ នាក់។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ២. ការងារគ្រប់គ្រងរដ្ឋបាល៖

- បានទទួលលិខិតចូល ចំនួន ២,១៦៨ លិខិត
- បានចុះលិខិតចេញ ចំនួន ១,៣០៤ លិខិត
- បានរៀបចំលិខិតបញ្ជាបេសកកម្មបានចំនួន២៨៦ លិខិត
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការមន្ទីរបានចូលរួមកិច្ចប្រជុំសំខាន់ៗក្នុងខេត្តបានចំនួន ២២៣លើក ។
- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការមន្ទីរបានចូលរួមកិច្ចប្រជុំសំខាន់ៗក្រៅខេត្តបានចំនួន ៣១ លើក។
- បានរៀបចំស្នើសុំតែងតាំងមន្ត្រីរាជការចំនួន០៨ នាក់ ស្រី០២ នាក់ ។
- បានរៀបចំធ្វើប័ណ្ណមន្ត្រីរាជការមន្ទីរចំនួន១៩ នាក់ ស្រី០៦ នាក់ ។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៣.ការងារក្របខណ្ឌ និងបណ្តុះបណ្តាល៖

- បានរៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ជូនមន្ត្រីរាជការស៊ីវិលក្នុងខេត្ត បានចំនួន០៣ លើក មានមន្ត្រីរាជការចូលរួមសរុបចំនួន៣០១ នាក់ ស្រី៦៥ នាក់។
- បានបញ្ជូនមន្ត្រីរាជការមន្ទីរចំនួន១៤ នាក់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានា ចំនួន០៨ លើក ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ ។
- មន្ទីរបានបញ្ជូនមន្ត្រីរាជការចំនួន០៥ នាក់ ចូលរួមក្នុងសមាសភាពគណៈកម្មការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតបឋមគ្រូបង្រៀនកម្រិតមូលដ្ឋាន និងការប្រឡងថ្នាក់ពន្លឿន ។
- មន្ទីរបានរៀបចំបង្កើតក្រុមការងាររួម រវាងមន្ទីរមុខងារសាធារណៈខេត្តព្រៃវែង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង ដើម្បីចុះពិនិត្យការប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរពេល និងគ្រូបង្រៀនជាប់កិច្ចសន្យា លើសចំនួន ១២៤ នាក់ នៅតាមស្រុកចំនួន១១ ស្រុក។

# ៣.ការងារក្របខណ្ឌ និងបណ្ដុះបណ្ដាល៖(ត)

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ ខេត្តព្រៃវែង

- មន្រ្តីរាជការមន្ទីរចំនួន ០៦នាក់ បានចូលរួមសហការជាមួយក្រុមការងារអគ្គាធិការក្រសួងមុខងារសាធារណៈ ដើម្បីចុះពិនិត្យការបំពេញការងារមន្ត្រីរាជការក្របខណ្ឌពិសេស ចំនួន១៩១ នាក់ របស់មន្ទីរសុខាភិបាលខេត្តព្រៃវែង ។
- បានពិនិត្យស្ម័យប្រកាស និងបញ្ចូលទិន្នន័យមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរ-អង្គភាពនានាជុំវិញខេត្ត បានចំនួន៤៣៤ នាក់ ស្រី១៤៨ នាក់ ក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ។
- បានត្រួតពិនិត្យស្ម័យប្រកាស និងផ្តល់ទិដ្ឋាការជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ឱ្យប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរពេល គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា សរុបចំនួន២,៣៤០ នាក់ ស្រី៨៩៣ នាក់។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៣.ការងារក្របខណ្ឌ និងបណ្ដុះបណ្ដាល៖(ត)

- បានត្រួតពិនិត្យស្វ័យប្រកាស និងផ្ដល់ទិដ្ឋាការជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ឱ្យប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធទាំង០៤កម្មវិធី សរុបចំនួន១៦៦ នាក់ ស្រី៥៨ នាក់ ។
- បានចុះពិនិត្យវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៅតាមមន្ទីរ-អង្គភាពនានាជុំវិញខេត្ត បានចំនួន១០ មន្ទីរ-អង្គភាព ស្មើនឹងចំនួន៨៩៨ នាក់ ស្រី២២៣ នាក់ ។
- បានចុះពិនិត្យការប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរពេល ថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យាចំណោះទូទៅ បានចំនួន០៦ ស្រុក ស្មើនឹងចំនួន១៣សាលា ។
- បានចុះពិនិត្យការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ បានចំនួន០៣ ស្រុក ស្មើនឹងចំនួន១០ ថ្នាក់ ។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៣.ការងារក្របខណ្ឌ និងបណ្ដុះបណ្ដាល៖( ត )

- ថ្នាក់ដឹកនាំមន្ទីរបានចូលរួមប្រជុំតែងតាំងមន្ត្រីរាជការស៊ីវិល ជាមួយគណៈអភិបាលខេត្ត ចំនួន០៤ លើក ចេញដីកាចំនួន៣២ ដីកា សរុបមន្ត្រីចំនួន ១៥២ នាក់ ។
- បានចាត់មន្ត្រីចូលរួមសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡា ចំនួន០៤ ស្រុក ដើម្បីពិនិត្យវាយតម្លៃជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ចំណោះទូទៅចំនួន១២០ នាក់ ស្រី៥៩ នាក់ សម្រាប់ប្រើប្រាស់ឆ្នាំ ២០១៩។
- បានចូលរួមសម្របសម្រួលរៀបចំឯកសារប្រជុំវាយតម្លៃ ជ្រើសរើសអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ ចំនួន០៥ លើក ។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៤. ការងារត្រួតពិនិត្យរដ្ឋបាល និងបៀវត្សរ៍

- មន្ត្រីរាជការស៊ីវិលទូទាំងខេត្តសរុបចំនួន១០,៩១៥ នាក់ស្រីមានចំនួន ៤,៣១៤នាក់។
- សហព័ទ្ធមន្ត្រីរាជការស៊ីវិល សរុបចំនួន៣,៩៧២ នាក់។
- កូនមន្ត្រីរាជការស៊ីវិល សរុបចំនួន១២,៣៤៨ នាក់ ។
- បានពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណុំឯកសារបៀវត្ស ប្រចាំឆ្នាំ២០១៨ ជូនមន្ទីរ-អង្គភាពនានាជុំវិញខេត្ត ចំនួន២៥ មន្ទីរ-អង្គភាព និង១៣ក្រុង-ស្រុក ។
- ឥណទានបៀវត្សសរុបទូទាំងខេត្ត ប្រចាំឆ្នាំ២០១៨ ស្មើនឹង ១៨៤,០៧៨,០១៧,៨២២ រៀល (មួយរយប៉ែតសិបបួនពាន់ ចិតសិបប្រាំបីលាន ដប់ប្រាំពីរពាន់ ប្រាំបីរយម្ភៃពីររៀលគត់)។

# ៤. ការងារត្រួតពិនិត្យរដ្ឋបាល និងបៀវត្សរ៍(ត)

ក្រសួងមុខងារសាធារណៈ
មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង

- បៀវត្សមន្ត្រីដែលត្រូវបង់ពន្ធទូទាំងខេត្ត ប្រចាំឆ្នាំ២០១៨ ស្មើនឹង ៤៨១,៨៤៦,៣៨១ រៀល(បួនរយប៉ែតសិបមួយលាន ប្រាំបីរយសែសិបប្រាំមួយពាន់ បីរយប៉ែតសិបមួយរៀលគត់)។
- បានចុះពិនិត្យករណីស្នើសុំរំលឹកបៀវត្សលើសពី០៣ ខែបានចំនួន០៤ មន្ទីរ-អង្គភាពមន្ត្រីរាជការស៊ីវិល ចំនួន០៧ នាក់។
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយការស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិល ជូនសាលាក្រុង-ស្រុកទាំង១៣ មានមន្ត្រីចូលរួមចំនួន៥៧ នាក់ ។
- បានបញ្ចូលទិន្នន័យ និងបោះពុម្ពតារាងបើកផ្តល់ប្រាក់ម៉ោងបន្ថែមជូនលោកគ្រូ-អ្នកគ្រូចំនួន៩១ សាលា រយៈពេល១០ ខែ មានរបបម៉ោងបន្ថែមចំនួន ៤៦៣,៨០០ ម៉ោង មានទឹកប្រាក់ត្រូវបើកចំនួន៣,០៥៤,៣២៣,១៥២ រៀល (បីពាន់ហាសិបបួនលាន បីរយម្ភៃបីពាន់ មួយរយហាសិបពីររៀលគត់)។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៤. ការងារត្រួតពិនិត្យរដ្ឋបាល និងបៀវត្ស៖(ត)

- បានរៀបចំសេចក្តីជូនដំណឹងឱ្យមន្ទីរ-អង្គភាពចំនួន០៨ បង្វែរប្រាក់បៀវត្ស ដែលបើកលើសបង់ចូលថវិការដ្ឋវិញ ដែលមានទឹកប្រាក់ចំនួន **១៩១,៩៥៩,៣០០ រៀល(មួយរយកៅសិបមួយលាន ប្រាំបួនរយហាសិប ប្រាំបួនពាន់ បីរយរៀលគត់)។**
- បានពិនិត្យ និងសម្រេចការស្នើសុំផ្តាច់បៀវត្សករណីមន្ត្រីផ្ទេរក្រៅក្របខណ្ឌ ចេញបានចំនួន០៩ មន្ទីរ-អង្គភាព និងចំនួន០២ ក្រុង-ស្រុក មានមន្ត្រីរាជការសរុបចំនួន១៥១ នាក់ ស្រី៥៨ នាក់ ។
- បានពិនិត្យ និងសម្រេចផ្តល់ទិដ្ឋាការការស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំបានចំនួន២៥ មន្ទីរ-អង្គភាព និងចំនួន១០ ក្រុង-ស្រុក ស្មើនឹង១៤,២៨៩ ករណី ។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង

# ៥. បញ្ហាប្រឈម៖

- មន្ទីរ-អង្គភាពមួយចំនួនពេលទទួលបានសេចក្តីជូនដំណឹង ស្តីពីការបង្វែរប្រាក់បៀវត្ស ហើយមានការយឺតយ៉ាវក្នុងការបញ្ជូនសំណែសចំណាយត្រឡប់មកវិញ។
- ក្រុង-ស្រុកមួយចំនួនមានការយឺតយ៉ាវ ក្នុងការមកទទួលយកតារាងបើកផ្តល់ប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យា ។
- មន្ទីរ-អង្គភាព និងក្រុងស្រុកមួយចំនួនមានការយឺតយ៉ាវក្នុងការបញ្ជូនរបាយការណ៍នៃការស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលមកមន្ទីរមុខងារសាធារណៈខេត្ត។
- ខ្វះមធ្យោបាយធ្វើដំណើរក្នុងការចុះបំពេញបេសកកម្ម។
- សមត្ថភាពមន្ត្រីរាជការមានការយល់ដឹងពីច្បាប់ និងជំនាញនៅមានកម្រិត។
- មន្ត្រីជំនាញតាមមន្ទីរ-អង្គភាព និងសាលាក្រុង-ស្រុកមួយចំនួនការយល់ដឹងនៅមានកម្រិត លើការការងាររៀបចំកំណែបៀវត្សមកមន្ទីរមុខងារសាធារណៈខេត្ត។

ក្រសួងមុខងារសាធារណៈ
មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៦. ទិសដៅបន្ត៖

- បន្តទំនាក់ទំនង និងសហការល្អ ជាមួយគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត មន្ទីរ-អង្គភាពនានាជុំវិញខេត្ត និងសាលាក្រុង-ស្រុក ។
- បន្តពិនិត្យសំណុំឯកសារការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលរបស់មន្ទីរ-អង្គភាពទាំង២៥ និង១៣ ក្រុង-ស្រុក។
- បន្តរៀបចំលិខិតជូនដំណឹង ដល់មន្ទីរ-អង្គភាព ដែលត្រូវបង្វែរបៀវត្សចូលរដ្ឋវិញ។
- បន្តចុះពិនិត្យវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ការប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរពេល ថ្នាក់គួប គ្រូបង្រៀនជាប់កិច្ចសន្យាចំណោះទូទៅ គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងការប្រើប្រាស់ប្រាក់ម៉ោងបន្ថែមរបស់មន្ទីរ-អង្គភាពនានាជុំវិញខេត្ត។

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

# ៦. ទិសដៅបន្ត៖(ត)

- បន្តប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ជូនមន្ត្រីរាជការក្នុងខេត្ត ។
- បន្តបញ្ចូលព័ត៌មានមន្ត្រីជាប់កិច្ចសន្យា នៅតាមមន្ទីរ-អង្គភាព និងក្រុង-ស្រុក ចូលក្នុងប្រព័ន្ធគ្រប់គ្រងមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងមុខងារសាធារណៈ។
- បន្តពិនិត្យ និងបញ្ចូលទិន្នន័យរបបម៉ោងបន្ថែមរបស់វិទ្យាល័យ-អនុវិទ្យាល័យ ទៅក្នុងប្រព័ន្ធគ្រប់គ្រងប្រាក់ម៉ោងបន្ថែម ទាន់ពេលវេលា។

# ៧. សំណូមពរ៖

ក្រសួងមុខងារសាធារណៈ

មន្ទីរមុខងារសាធារណៈ
ខេត្តព្រៃវែង

- ស្នើសុំអគាររដ្ឋបាល ចំនួន០១ ខ្នង ។

**សូមអរគុណ!**